# ប្រធានបទ

## ក្នុងនាមជាយុវជន ឬយុវនារីម្នាក់នៅក្នុងជំនាន់នេះនិងជាមេដឹកនាំម្នាក់នៅជំនាន់ក្រោយ

## តើអ្នកអាចចូលរួមចំណែកដូចម្តេចខ្លះដើម្បីប្រទេសកម្ពុជា?

-ឈ្មោះ **នៅ សករាជ** Nov Sakarach

-ភេទ **ប្រុស** អាយុ **២១ឆ្នាំ**

-ថ្ងៃខែឆ្នាំកំណើត **០១ កុម្ភៈ ១៩៨៩**

-ទីកន្លែងកំណើត ភូមិៈ **តាប** ឃុំៈ **ទឹកថ្លា** ស្រុកៈ **សិរីសោភ័ណ** ខេត្តៈ **បន្ទាយមានជ័យ** ។

**ជានិស្សិតឆ្នាំទី២ ជំនាញនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច(Rule)ហើយក៏ជានិស្សិតឆ្នាំទី២ជំនាញទំនាក់ទំនងអន្តរជាតិនៅសាកលវិទ្យាល័យកម្ពុជា(UC)**

-អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខៈ**១៣២** ផ្លូវៈ**១៣៨** សង្កាត់ៈ **ទឹកល្អក់ I** ខណ្ឌៈ **ទួលគោក** រាជធានី **ភ្នំពេញ** ។

-លេខទូរស័ព្ទៈ **០៨៩ ៨៩២ ៨៥៦** ឬ **០៩៨ ៩៦២ ៩៣១**

Email : skr_nov@yahoo.com

# សេចក្ដីសង្ខេបអត្ថបទ

កម្ពុជាគឺជារាជបូរីអច្ឆរិយដ៏អស្ចារ្យមួយដែលទើបតែងើបចេញពីសង្គ្រាមផ្ទៃក្នុងរ៉ាំរ៉ៃជាច្រើនទសវត្សរ៍ តែទីបំផុតកម្ពុជាបានធ្វើការបង្រួបបង្រួមប្រទេសរបស់ខ្លួនវិញយ៉ាងជោគជ័យដោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ ហើយ បានបន្តធ្វើសមាហរណកម្មក្រុមឧទ្ទាមខ្មែរក្រហមយ៉ាងជោគជ័យទៀតនៅឆ្នាំ ១៩៩៨ ដោយគោលនយោបាយឈ្នះឈ្នះរបស់រាជរដ្ឋាភិបាល កម្ពុជានាអណត្តិទីមួយនៃរដ្ឋសភា។ មិនខុសពីប្រទេសនានានៅលើសកលលោកនោះទេ ប្រទេសកម្ពុជាស្វែងរកសន្តិភាព ស្ថេរភាព សុវត្ថិភាពទាំងផ្នែកសន្តិសុខសង្គម នយោបាយ ការទូត និងសេដ្ឋកិច្ចមករក្សាទុកក្នុងប្រទេសរបស់ខ្លួន គឺដោយសារចង់អភិវឌ្ឍប្រទេស មួយនេះប្រកបទៅដោយនិរន្តរភាព និងវឌ្ឍនភាព។ ដូចនេះវាទាមទារនូវការចូលរួមចំណែកយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋរបស់ខ្លួន គ្រប់ៗរូបជាពិសេសគឺក្រុមស្រទាប់យុវជនដែលជាកោសិការដ៏សំខាន់មួយនៃសង្គម ប្រៀបដូចជាពាក្យមួយឃ្លាដែលគេតែងតែលើកឡើងថា ***"យុវជនគឺជាកម្លាំងស្នូលនៃការអភិវឌ្ឍន៍ជាតិ "***។ ដូចនេះក្នុងនាមជាយុវជន ឬយុវនារីម្នាក់នៅជំនាន់នេះ និងជាមេដឹកនាំម្នាក់នៅក្នុងជំនាន់ ក្រោយ តើយើងអាចចូលរួមចំណែកដូចម្ដេចខ្លះដើម្បីប្រទេសកម្ពុជា?

យុវជនពិតជាមានសារៈសំខាន់ណាស់ក្នុងការចូលរួមដឹកនាំ កសាង កែប្រែ អភិវឌ្ឍន៍ប្រទេសជាតិ ពោលយុវជនគឺជាកំលាំងចលករ កំលាំងស្នូល កំលាំងមូលដ្ឋាន កំលាំងអភិវឌ្ឍន៍ដ៏សំខាន់នៃប្រទេសជាតិមួយ។ ហើយក្នុងនាមខ្ញុំជាយុវជនម្នាក់នៅជនាន់នេះ និងជាមេដឹកនាំម្នាក់នៅថ្ងៃអនាគត ខ្ញុំអាចចូលរួមសកម្មភាពបានយ៉ាងច្រើនទៅលើការកសាង និងអភវឌ្ឍន៍ប្រទេសកម្ពុជា។ ការចូលរួមទាំងនោះសម្រាប់ខ្ញុំមានបីដំណាក់កាល គឺ **ការអភិវឌ្ឍន៍ខ្លួនឯង ការចូលរួមអភិវឌ្ឍន៍គ្រួសារ និងការចូលរួមអភិវឌ្ឍន៍សង្គម។** ប្រហែលជាលោកអ្នកអាចនឹងឆ្ងល់ហើយថា ហេតុអ្វីបានជាខ្ញុំចូលរួមសកម្មភាពជួយកម្ពុជាតែបែរជាទៅអភិវឌ្ឍខ្លួនឯង និងអភិវឌ្ឍគ្រួសារមុនការចូលរួមអភិវឌ្ឍន៍សង្គមជាតិទៅវិញ? ដូចដែលយើងដឹងស្រាប់មកហើយថានៅក្នុងសង្គមជាតិមួយមានសង្គមគ្រួសារដែលជាកោសិកា ហើយនៅក្នុងសង្គមគ្រួសារមានបុគ្គលគ្រប់ៗរូបទាំងប្រុសទាំងស្រីដែលជាសមាជិកដ៏សំខាន់របស់គ្រួសារ។ ដូចនេះហើយបើចង់ឱ្យសង្គមជាតិមួយរីកចំរើនលូតលាស់ ជឿនលឿន អភិវឌ្ឍទៅមុខបានលុះត្រាតែនៅក្នុងសង្គមគ្រួសារទាំងអស់ដែលជាកោសិកានៃសង្គមជាតិនោះមានលក្ខណៈល្អ ប្រសើរ មានជីវភាពសមរម្យ មានការចុះសំរុងគ្នា មានការយោគយល់គ្នាពោលគឺមានសុភមង្គលប្រកបដោយភាពសុខកាយសប្បាយចិត្ត។ យ៉ាងណាមិញ បើចង់ឱ្យសង្គមគ្រួសារទាំងនោះមាននូវជីវភាពធូរធារ មានសុភមង្គល មានកម្លាំងខ្លាំងក្លាលូតលាស់ទៅបាននោះលុះត្រាតែសមាជិកម្នាក់ៗនៅក្នុងគ្រួសារនោះមានសុខភាពល្អ មានចំនេះដឹង មានសមត្ថភាព មានសីលធម៌គុណធម៌ មានការងារសមស្របសមរម្យ និងមានការគោរពគ្នាទៅវិញទៅមកដែលប្រកបទៅសតិស្មារតីភ្ជាក់រលឹកជាប់ជានិច្ច។

ការអភិវឌ្ឍន៏ខ្លួនឯង គឺខ្ញុំត្រូវតែជាមនុស្សដែលមាន**ចំណេះដឹង សមត្ថភាព និងមានក្រមសីលធម៌**ប្រកបដោយឧត្ដមគតិយ៉ាងភ្លឺថ្លា ។ ហើយបន្ទាប់ពីការអភិវឌ្ឍន៏ខ្លួនឯង ខ្ញុំត្រូវតែមានការអភិវឌ្ឍន៏ក្រុមគ្រួសារដោយមាន **ការគិត ការនិយាយ និងការធ្វើ** ពោលគឺខ្ញុំត្រូវតែ ដឹង

និងគោរពសិទ្ធិ គោរពតួនាទីគ្នាទៅវិញទៅមកនៅក្នុងគ្រួសារដោយស្មារតីសាមគ្គីភាពខ្ពស់បំផុត។ ក្រៅពីនេះទៀតខ្ញុំត្រូវចូលរួមក្នុងសកម្មភាពដើម្បីអភិវឌ្ឍន៍សង្គមជាតិយើងដោយ **ការគោរពច្បាប់គោរពវិន័យសង្គម ការចូលរួមសកម្មភាពនានានៅក្នុងសង្គម និងការចូលរួមបណ្តុះបណ្តាលអ្នកជំនាន់ក្រោយ**ដើម្បីឱ្យពួកគេធ្វើជាអ្នកស្នងមរតកនៃតួនាទី និងកាតព្វកិច្ចក្នុងការដឹកនាំប្រទេសជាតិយើងឱ្យមានការរីកចំរើនទៅមុខជាលំដាប់នាពេលអនាគត់ និងដើម្បីឱ្យកម្ពុជាយើងអាចធ្វើសមាហរណកម្មខ្លួនចូលទៅក្នុងដំបន់ ក៏ដូចជាក្នុងសកលលោកនៃពិភពសកលភាវូបនីយកម្មយើងនេះ។

### ការចូលរួមរបស់ខ្ញុំដើម្បីកម្ពុជា

- -ការអភិវឌ្ឍន៍ខ្លួនឯង
  - -សុខភាព
  - -សមត្ថភាព ចំនេះដឹង ចំនេះធ្វើ
  - -គុណធមិ សីលធមិ
- -ការចូលរួមអភិវឌ្ឍន៍គ្រួសារ
  - -ការគិត (វិភាគ)
  - -ការនិយាយ
  - -ការធ្វើ ការអនុវត្តន៍
- -ការចូលរួមអភិវឌ្ឍន៍សង្គម
  - -ការគោរពច្បាប់ វិន័យសង្គម
  - -ការចូលរួមសកម្មភាពនានាក្នុងសង្គម
  - -ការចូលរួមបណ្តុះបណ្តាលអ្នកជំនាន់ក្រោយ

# សេចក្តីអត្ថាធិប្បាយ

កម្ពុជាគឺជារាជបូរីអច្ឆរិយដ៏អស្ចារ្យមួយដែលទើបតែងើបចេញពីភ្នក់ភ្លើងសង្គ្រាមផ្ទៃក្នុងរាំរ៉ៃជាច្រើនទសវត្សរ៍ តែទីបំផុតកម្ពុជា បានធ្វើការបង្រួបបង្រួមប្រទេសរបស់ខ្លួនវិញយ៉ាងជោគជ័យដោយកិច្ចព្រមព្រៀងសន្តិភាពនាទីក្រុងប៉ារីស ថ្ងៃ២៣ ខែតុលា ឆ្នាំ១៩៩១។ ហើយបានបន្តធ្វើសមាហរណកម្មក្រុមឧទ្ទាមខ្មែរក្រហមយ៉ាងជោគជ័យទៀតនៅឆ្នាំ ១៩៩៨ ដោយគោលនយោបាយឈ្នះឈ្នះរបស់រាជ រដ្ឋាភិបាលកម្ពុជានាអណត្តិទីមួយនៃរដ្ឋសភា។ មិនខុសពីប្រទេសនានានៅលើសកលលោកនេះឡើយ ប្រទេសកម្ពុជាស្វែងរកសន្តិភាព ស្ថេរភាព សុវត្ថិភាព ទាំងផ្នែកសន្តិសុខសង្គម នយោបាយ ការទូត និងសេដ្ឋកិច្ចមករក្សាទុកក្នុងប្រទេសរបស់ខ្លួន គឺដោយសារចង់អភិវឌ្ឍ ប្រទេសមួយនេះប្រកបទៅដោយនិរន្តរភាព និងវឌ្ឍនភាព។ ដូចនេះវាទាមទារនូវការចូលរួមចំណែកយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋ គ្រប់ៗរូបរបស់ខ្លួន ជាពិសេសគឺក្រុមស្រទាប់យុវជនដែលជាកោសិកាដ៏សំខាន់មួយនៃសង្គមប្រៀបដូចជាពាក្យមួយឃ្លាដែលគេតែងតែលើក ឡើងថា "***យុវជនគឺជាកម្លាំងស្នូលនៃការអភិវឌ្ឍន៍ជាតិ***"។ ដូចនេះក្នុងនាមជាយុវជន ឬយុវនារីម្នាក់នៅជំនាន់នេះ និងជាមេដឹកនាំម្នាក់នៅក្នុង ជំនាន់ក្រោយ តើយើងអាចចូលរួមចំណែកដូចម្តេចខ្លះដើម្បីប្រទេសកម្ពុជា?

## និយមន័យពាក្យគន្លឹះ

ជាដំបូងមុននឹងយើងឈានចូលទៅដល់ការបកស្រាយ ជជែកវែកញែក ពិភាក្សាទៅលើប្រធានបទខាងលើឱ្យបានកាន់តែក្បោះ ក្បាយ និងស៊ីជម្រៅនោះ ខ្ញុំសូមធ្វើការអនុញ្ញាតលើកយកពាក្យគន្លឹះសំខាន់ៗនៅក្នុងប្រធានបទខាងលើមកពន្យល់បកស្រាយជាមុនសិន។ ពាក្យគន្លឹះសំខាន់ៗនៅក្នុងប្រធានបទខាងលើដែលនឹងត្រូវបានយកមកបកស្រាយនោះគឺ ពាក្យ**យុវជន** និង ពាក្យ**មេដឹកនាំ**។

**យុវជន** គឺមានអត្ថន័យទូលំទូលាយនៅក្នុងផ្នែកសង្គម វប្បធម៌ និងនយោបាយនៃប្រទេសកម្ពុជា រីឯការប្រើពាក្យ **យុវជន** គោលនយោបាយជាតិយុវជនកម្ពុជាបានផ្តោតលើ **មនុស្សវ័យក្មេង ឬ បុរស ស្ត្រីវ័យក្មេង** គ្រប់ជនជាតិដែលមានសញ្ជាតិខ្មែរចាប់ពីអាយុ១៥ ឆ្នាំ ទៅដល់ ៣០ឆ្នាំ។ យុវជនជាវ័យដែលមានការប្រែប្រួលយ៉ាងឆាប់រហ័សទាំងរូបរាង្គកាយ បញ្ញា ស្មារតី និងជាធនធានដ៏សំខាន់ ជាគន្លឹះ នៃការប្រែប្រួលសេដ្ឋកិច្ច ជាពលរដ្ឋសកម្ម និងជាអ្នកដឹកនាំសម្រាប់ថ្ងៃអនាគត។ ការចូលរួមរបស់យុវជនធ្វើឱ្យសង្គមជាតិមានអនាគត រុងរឿង[1]។

**មេដឹកនាំ** ជាប្រភេទមនុស្សដែលមានលទ្ធភាព និងចំនេះដឹងគ្រប់គ្រាន់ ហើយនឹងឥទ្ធិពលយ៉ាងខ្លាំងគ្របដណ្តប់ទៅលើអ្នកដទៃ មិនតែប៉ុណ្ណោះមានសមត្ថភាពក្នុងការរៀបចំសកម្មភាពការងាររួមដើម្បីធ្វើឱ្យសំរេចបំណងដែលបានកំណត់[2]។អ្នកដឹកនាំមានជាច្រើនប្រភេទ ដូចជាអ្នកដឹកនាគ្រួសារ អ្នកដឹកនាំក្រុម អ្នកដឹកនាំបក្ស អ្នកដឹកនាំសហគមន៍ អ្នកដឹកនាំសមាគមន៍ អ្នកដឹកនាំតំបន់ អ្នកដឹកនាំភូមិភាគ

[1] សេចក្តីព្រាង គោលនយោបាយជាតិយុវជនកម្ពុជា ២០០៩ ទំព័រទី៣

[2] ឈុន ណារ៉េត "សេចក្តីផ្តើមវិទ្យាសាស្ត្រនយោបាយ" ភ្នំពេញ ព.ស ២៥៥៣ គ.ស ២០០៨ កែសម្រួល និងបោះពុម្ពផ្សាយលើកទី៣ ទំព័រ ១២១

អ្នកដឹកនាំប្រទេស និងអ្នកដឹកនាំពិភពលោក។ ទោះបីជាយើងមើលទៅហាក់ដូចជាមានប្រភេទអ្នកដឹកនាំជាច្រើនបែបនេះក៏ដោយ តែតាមពិតទៅអ្នកដឹកនាំត្រូវបានគេបែងចែកចេញជាពីរប្រភេទប៉ុណ្ណោះ គឺ **អ្នកដឹកនាំខ្លួនឯង និងអ្នកដឹកនាំអ្នកដទៃ**[៣] ។

ក្រោយពេលដែលយើងបានធ្វើការសិក្សាស្វែងយល់ពីអត្ថន័យនៃពាក្យគន្លិះសំខាន់ៗនៅក្នុងប្រធានបទខាងលើរួចហើយនោះ យើង បានសន្និតឃើញថា យុវជនពិតជាមានសារៈសំខាន់ណាស់ក្នុងការចូលរួមដឹកនាំ កសាង កែប្រែ អភិវឌ្ឍប្រទេសជាតិ ពោលយុវជនគឺជាកម្លាំងចលករ កម្លាំងស្នូល កម្លាំងមូលដ្ឋាន កម្លាំងអភិវឌ្ឍន៍ដ៏សំខាន់ដល់ប្រទេសជាតិមួយ។ ហើយក្នុងនាមខ្ញុំជាយុវជនម្នាក់នៅជនាន់នេះ និងជាមេដឹកនាំម្នាក់នៅថ្ងៃអនាគត់ ខ្ញុំអាចចូលរួមសកម្មភាពយ៉ាងច្រើនទៅលើការកសាង និងអភវឌ្ឍន៍ប្រទេសកម្ពុជា។ ការចូលរួមទាំងនោះសម្រាប់ខ្ញុំមានបីដំណាក់កាល គឺ **ការអភិវឌ្ឍន៍ខ្លួនឯង ការអភវឌ្ឍន៍គ្រួសារ និង ការអភិវឌ្ឍន៍សង្គម។** ប្រហែលជាលោកអ្នកអាចនឹងឆ្ងល់ហើយថាហេតុអ្វីបានជាខ្ញុំចូលរួមសកម្មភាពជួយកម្ពុជាតែបែរជាទៅអភិវឌ្ឍខ្លួនឯង និងអភិវឌ្ឍគ្រួសារមុនការចូលរួមអភិវឌ្ឍន៍សង្គមជាតិទៅវិញ? ដូចដែលយើងដឹងស្រាប់មកហើយថានៅក្នុងសង្គមជាតិមួយមានសង្គមគ្រួសារដែលជាកោសិកា ហើយនៅក្នុងសង្គមគ្រួសារមានបុគ្គលគ្រប់ៗរូបទាំងប្រុសទាំងស្រីដែលជាសមាជិកគ្រួសារ។ ដូចនេះហើយបើចងឱ្យសង្គមជាតិមួយរីកចំរើនលូតលាស់ជឿនលឿនអភិវឌ្ឍទៅមុខបានលុះត្រាតែនៅក្នុងសង្គមគ្រួសារទាំងអស់ដែលជាកោសិកានៃសង្គមជាតិនោះមានលក្ខណៈល្អប្រសើរមានជីវភាពសមរម្យ មានការចុះសំរុងគ្នា មានការយោគយល់គ្នា ពោលគឺមានសុភមង្គលប្រកបដោយភាពសុខកាយសប្បាយចិត្ត។ យ៉ាងណាមិញបើចង់ឱ្យសង្គមគ្រួសារទាំងនោះមាននូវជីវភាពធូរធារ មានសុភមង្គល មានកម្លាំងខ្លាំងក្លាបាននោះលុះត្រាតែសមាជិកម្នាក់ៗនៅក្នុងគ្រួសារនោះមានសុខភាពល្អ មានចំនេះដឹង មានសម្ថតភាព មានសីលធម៌គុណធម៌ មានការងារសមស្របសមរម្យ និងមានការគោរពគ្នាទៅវិញទៅមកដែលប្រកបទៅដោយសតិស្មារតីភ្ញាក់រលឹក និងសាមគ្គីភាពខ្ពស់បំផុត។

## ការចូលរួមអភិវឌ្ឍន៍ខ្លួនឯង

ការអភិវឌ្ឍន៍ខ្លួនឯងមានមានពីរចំនុចសំខាន់ៗដែលខ្ញុំនឹងលើកយកមកបកស្រាយ។ ទីមួយនោះគឺ **សុខភាពដែលជាកត្តាសំខាន់បំផុតសម្រាប់យុវជន** ហើយដែលមនុស្សគ្រប់គ្នាត្រូវការវាមិនអាចខ្វះបានទាំងសុខភាពផ្លូវកាយ សុខភាពផ្លូវចិត្ត និងប្រាជ្ញាស្មារតី ប្រៀបដូចជាពាក្យមួយឃ្លាដែលគេតែងតែលើកឡើងជាសកលថា ***"សុខភាពជាអ្វីៗទាំងអស់ "។*** និង ទីពីរនោះគឺ **សមត្ថភាពចំនេះដឹង** ដែលមានទាំងចំនេះដឹង និងចំនេះធ្វើ។ សុខភាពពិតជាមានសារៈសំខាន់ណាស់សម្រាប់មនុស្សយើងម្នាក់ៗ ហើយវាជាអ្នកដែលធ្វើឱ្យយើងក្លាយជាមនុស្សមានកម្លាំងថាមពលខ្លាំងក្លាទាំងកម្លាំងកាយ កម្លាំងចិត្ត និងប្រាជ្ញាស្មារតីក្នុងការតស៊ូរប្រឆាំងជាមួយនឹងឧបសគ្គនានាដែលយើងបានជួបប្រទះក្នុងជីវិតនៃការរស់នៅ និងជីវិតការងារប្រចាំថ្ងៃរបស់យើង។ លើសពីនេះទៅទៀតនោះ វាធ្វើឱ្យយើងក្លាយជាកម្លាំងអភិវឌ្ឍន៍ និងកម្លាំងការពារជាតិដ៏ខ្លាំងក្លាមួយប្រៀបដូចជាបន្ទះដែកថែបដ៏រឹងមាំអស្ចារ្យ។ ក្រៅពីយើងមានសុខភាពល្អហើយ អ្វីដែលយើងកាន់តែមិនអាចខ្វះបានទៀតនោះ គឺសមត្ថភាពនៃចំនេះដឹងរបស់យើងដែលប្រៀបដូចជាពាក្យកំណាព្យភាសាខ្មែរយើងមួយឃ្លាដែលពោលឡើងថា ***"...កណ្ដៀវមិនកោរ កណ្ដុរមិនកាត់ ចោរលួចមិនបាត់ ចាយច្រើនចម្រើនទៀត..."។*** សមត្ថភាព និងចំនេះដឹងពិតជាសំខាន់ណាស់ ដូចនេះ

---

[3] តាមទស្សនៈអ្នកសរសេរអត្ថបទ

តើយើងធ្វើយ៉ាងណាទើបអាចមានសមត្ថភាព និងចំនេះដឹង? កុំប្រញាប់ពេក ! ការធ្វើអ្វីមួយត្រូវធ្វើដោយសន្សឹមៗព្រោះថាចំណេះដឹង និងសមត្ថភាពមិនមែនជាអ្វីដែលយើងថាចង់បានក៏បានភ្លាមនោះទេ គឺទាមទារឱ្យយើងមានការតស៊ូរព្យាយាម អត់ធ្មត់ និងមនសិការយ៉ាងមុះមុតបំផុត បើមិនដូចនោះទេយើងនឹងបរាជ័យមុនពេលដែលយើងទទួលបានវាមិនខាន ប្រៀបដូចជាពាក្យស្លោកខ្មែរយើងមួយឃ្លាបានលើកឡើងថា ***"តក់ៗពេញបំពង់ ស្រងៗកំពប់អស់"***។ សមត្ថភាព និងចំនេះដឹងមានសារៈសំខាន់បំផុតដែលយើងជាយុវជនកម្ពុជាគ្រប់ៗរូបត្រូវតែឈ្វេងយល់ឱ្យបានច្បាស់អំពីសារៈសំខាន់របស់វា គឺសំដៅទៅលើចំនេះដឹង និងចំនេះធ្វើព្រោះថាបន្ទាប់ពីការសិក្សាអំពីទ្រឹស្តីដែលជាចំនេះដឹងហើយនោះ ត្រូវមានការចុះអនុវត្តន៏ដែលជាចំនេះធ្វើថែមទៀត ។ វាមិនមែនជាអ្វីដែលលំបាកនោះទេព្រោះចំនេះដឹង និងចំនេះធ្វើរបស់មនុស្សយើងអាចសិក្សារៀនសូត្របានគ្រប់ទីកន្លែងទាំងអស់សូម្បីតែមនុស្សកំហូចម្នាក់ដែលនៅក្បែរខ្លួនយើង ក៏យើងអាចរៀនពីគេបានដែរ។ លើសពីនេះ ចំនេះដឹង និងសមត្ថភាពរបស់យើង យើងអាចស្វែងរកបានតាមរយៈការអប់រំផ្សេងៗទាំងការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធដែលមានដូចជា សាលារៀន សាកលវិទ្យាល័យ មជ្ឈមណ្ឌល អង្គការ វត្តអារាម ប្រព័ន្ធផ្សព្វផ្សាយនានាដូចជា វិទ្យុ ទូរទស្សន៍ ការសែត ទស្សនាវត្តី ។ល។

### ការចូលរួមអភិវឌ្ឍន៍គ្រួសារ

ដើម្បីចូលរួមអភិវឌ្ឍប្រទេសកម្ពុជាជាទីស្រលាញ់ និងដើម្បីថែរក្សាមរតកកេរ្តិ៍ដំណែលដែលបុព្វបុរសដូនតារបស់យើងបានបន្សល់ទុកអោយយើងទាំងអស់គ្នាថែរក្សានោះ យើងត្រូវតែមានឆន្ទៈ ទឹកចិត្ត មនសិកាពោពេញទៅដោយភាពក្លៀវក្លា ប្រាជ្ញាឈ្លាសវៃ ស្មារតីរឹងប៉ឹង និងចំនេះដឹងជ្រៅជ្រះ មានគុណធមិសីលធមិ ពោលគឺយើងជាយុវជនម្នាក់ដែលជាធនធានមានជីវិតរស់រវើកមួយដ៏សំខាន់សម្រាប់ប្រទេសជាតិយើង។ ហើយបន្ទាប់ពីយើងជាយុវជនដែលចេះអភិវឌ្ឍខ្លួនឯងហើយនោះ វាជាហេតុផល និងជាកាតព្វកិច្ចដែលមិនអាចបដិសេធបានមួយទៀត ក្នុងនាមយើងជាសមាជិកម្នាក់នៅក្នុងគ្រួសារដែលជាកោសិកាដ៏តូចមួយនៅក្នុងសង្គមតែមានឥទ្ធិពលនោះ យើងត្រូវតែមានការរៀបចំ និងទំនួលខុសត្រូវខ្ពស់បំផុតនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើង។ នៅក្នុងគ្រួសារមួយដែលអាចមានការអភិវឌ្ឍន៏រីកចំរើនលូតលាស់ និងមានសុភមង្គលទៅបានគឺអាស្រ័យដោយមានការចូលរួមពីសំណាក់សមាជិកគ្រប់ៗរូបនៅក្នុងគ្រួសារ ជាពិសេសគឺក្រុមយុវជនដែលជាសមាជិក ហើយដែលជាអនាគតអ្នកដឹកនាំគ្រួសារមួយ។ ហើយដើម្បីអភិវឌ្ឍគ្រួសារមួយឱ្យមានភាពល្អប្រសើរនោះទាមទារអោយយើងដែលជាសមាជិកត្រូវបំពេញនូវតួនាទីរៀងៗខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់បំផុត។ យើងត្រូវដឹងថាក្នុងនាមយើងជាឪពុកម្តាយមានតួនាទីអ្វីខ្លះ? យើងជាកូន ជាបង ជាប្អូនមានតួនាទីបែបណាខ្លះ? យើងត្រូវចេះបើកចិត្តឱ្យទូលាយ ចេះជួយគ្នាទៅវិញទៅមក ចេះអធ្យាស្រ័យ និងយោគយល់គ្នា មិនត្រូវគិតចាំតែចាប់កំហុសគ្នាទៅវិញទៅមក ឬចាំតែចាប់ទោសអួសបន្ទាយគ្នានេះឡើយ។ ហើយសម្រាប់ខ្ញុំដែលជាសមាជិកម្នាក់ក្នុងគ្រួសារ និងអនាគតជាអ្នកដឹកនាំគ្រួសារម្នាក់ ខ្ញុំមានគោលការណ៍ **៣** សំខាន់ៗដើម្បីអោយគ្រួសាររបស់ខ្ញុំអាចអភិវឌ្ឍ រីកចំរើនលូតលាស់ និងមានសុភមង្គល។ គោលការណ៍ទាំង៣នោះគឺ **គិត និយាយ និងធ្វើ** ដែលជាគោលការណ៍ ឬកត្តាមូលដ្ឋានមិនអាចខ្វះបានសំរាប់បុគ្គលគ្រប់ៗរូបដែលចង់ធ្វើជាអ្នកដឹកនាំខ្លួនឯង និងអ្នកដទៃ ជាពិសេសដើម្បីដឹកនាំគ្រួសារនៅថ្ងៃអនាគត ។ នៅក្នុងគ្រួសារ ខ្ញុំត្រូវតែជាបុគ្គលម្នាក់ដែលចេះគិតគូរវិភាគ ប្រមើលមើល ពីចំនុចខ្លាំង ចំនុចខ្សោយ ចំនុចល្អ ចំនុចអាក្រក់ អ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើដើម្បីធ្វើឱ្យគ្រួសាររបស់ខ្ញុំអាចបន្តអត្ថិភាពនៅក្នុងសង្គមនេះបាន។

ខ្ញុំត្រូវប្រម៉ើលមើលពីអតីតកាល និងអនាគត កាលរបស់គ្រួសារខ្ញុំ និងចេះរៀបចំគោលដៅដើម្បីអភិវឌ្ឍទៅថ្ងៃអនាគត់ ពោលគឺមានការរៀបចំផែនការគ្រួសារជាប់ជាប្រចាំដែលជាការ

ល្អប្រសើរក្នុងការការពារទុកជាមុននូវហេតុភេទទាំងឡាយដែលអាចកើតឡើងដោយយើងមិនអាចប៉ាន់ស្មានទុកជាមុនបាន។ បន្ទាប់ពីខ្ញុំក្លាយជាបុគ្គលដែលចេះគិត ចេះវិភាគហើយនោះ ខ្ញុំត្រូវតែមានការនិយាយពិភាក្សាជាមួយគ្រួសាររបស់ខ្ញុំដើម្បីធ្វើការវែកញែកទាំងអស់គ្នាថាតើអ្វីជាបញ្ហា អ្វីមិនមែនជាបញ្ហា អ្វីដែលត្រូវដោះស្រាយ អ្វីមិនត្រូវដោះស្រាយ អ្វីជាអទិភាព អ្វីមិនមែនជាអទិភាព ពោលគឺនិយាយដោយបើកចំហរទៅបុគ្គលគ្រប់ៗរូបដែលជាសមាជិកនៅក្នុងគ្រួសារដើម្បីអោយបញ្ហាទាំងនោះត្រូវបានដឹងទាំងអស់គ្នា និងចូលរួមដោះស្រាយទាំងអស់គ្នា។ ដូចដែលយើងដឹងស្រាប់មកហើយថាគ្មានបញ្ហាណាដែលគ្មានដំណោះស្រាយនោះទេ ឱ្យតែយើងមានការចូលរួមទាំងអស់គ្នា យើងចេះរួបរួមគ្នា ចេះសាមគ្គីគ្នានោះយើងនឹងអាចដោះស្រាយវាបានដោយងាយស្រួល ប្រៀបដូចជាពាក្យមួយឃ្លាដែលបានលើកឡើងថា ***"សាមគ្គីគឺជាកត្តានៃភាពជោគជ័យ"*** ។ តែជាធម្មតាបន្ទាប់ពីយើងនិយាយពិភាក្សាគ្នារួចហើយ តែបើយើងមិនអនុវត្តន៏ដោះស្រាយ ឬដាក់ចេញជាផែនការសកម្មភាពទេនោះវានឹងក្លាយជាការឥតប្រយោជន៏ជាក់ជាមិនខាន ព្រោះថាជាតិជាសត្វមនុស្សយើងនេះត្រូវការមើលពីលទ្ធផលជាជាងការនិយាយអ្វីដែលឥតប្រយោជន៏។ ដូចនេះផែនការដោះស្រាយនិងការកំណត់ពីកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗក្នុងគ្រួសារត្រូវចេញឱ្យបានច្បាស់លាស់ទើបអាចទៅរួច ហើយគ្រួសារនោះនឹងអាចដោះស្រាយបញ្ហាបានដោយងាយស្រួលបំផុតព្រោះជាគ្រួសារមួយដែលមានរបៀបរយ មានការរៀបចំច្បាស់លាស់ មានសណ្តាប់ធ្នាប់ប្រៀបដូចជាពាក្យមួយឃ្លាដែលលើកឡើងថា ***"ក្បួនទាហ៊ានដែលមានសណ្តាប់ធ្នាប់ច្បាំងមួយរយដងឈ្នះមួយរយដង"*** ឬ ***"ក្រុមទាហ៊ានដែលមានរបៀបមួយរយនាក់ អាចយកឈ្នះទាហ៊ានដែលគ្មានរបៀបមួយពាន់នាក់ដោយងាយស្រួលនៅលើសមរភូមិ"*** ។ មានន័យថានៅក្នុងគ្រួសារមួយដែលមានកម្លាំងខ្លាំង មានកម្លាំងរឹងមាំ លុះត្រាតែយើងជាសមាជិកមានការគិត ការនិយាយ ការធ្វើទាំងអស់គ្នា ហើយក្នុងនាមខ្ញុំជាសមាជិកម្នាក់ ឬជាមេដឹកនាំគ្រួសារម្នាក់ទៅថ្ងៃអនាគតខ្ញុំត្រូវតែជាមនុស្សដែលមានរបៀបរៀបរយ មានការរៀបចំ ពោលគឺខ្ញុំត្រូវតែជាមនុស្សដែលមានចំនុចទាំងបីខាងលើនេះដើម្បីចូលរួមអភិវឌ្ឍគ្រួសារ និងធ្វើជាគំរូល្អៗសម្រាប់អ្នកជំនាន់ក្រោយដូចជាពាក្យមួយឃ្លាបានលើកឡើងថា ***"ទង្វើអ្នកមុនជាលទ្ធផលអ្នកក្រោយ"*** ។

## ការចូលរួមអភិវឌ្ឍន៍សង្គមជាតិ

ក្នុងនាមខ្ញុំជាយុវជនមួយរូបនាពេលបច្ចុប្បន្ន និងជាអនាគតនៃអ្នកដឹកនាំមួយរូបនាពេលអនាគត ខ្ញុំត្រូវតែជាបុគ្គលដ៏សំខាន់ម្នាក់នៅក្នុងការចូលរួមអភិវឌ្ឍន៏សង្គមជាតិរបស់ខ្ញុំ។ បន្ទាប់ពីខ្ញុំបានអភិវឌ្ឍខ្លួនឯង និងអភិវឌ្ឍគ្រួសាររបស់ខ្ញុំហើយ វាជាពេលដែលខ្ញុំត្រូវចូលរួមក្នុងការអភិវឌ្ឍន៏ប្រទេសជាតិខ្ញុំម្តង។ អាចត្រូវបានគេគិតថាវាជារឿងដ៏លំបាកមួយដែលក្នុងនាមខ្ញុំត្រឹមតែជាយុវជនវ័យក្មេងម្នាក់ ហើយចង់មកចូលរួមក្នុងការអភិវឌ្ឍន៏ប្រទេសជាតិដ៏ធំមួយ។ ហើយវាអាចត្រូវបានគេគិតថាគឺជាការនិយាយអោយរួចតែពីមាត់ប៉ុណ្ណោះ ។ បើដូចនេះតើយើងអាចចូលរួមដោយរបៀបណាដើម្បីប្រទេសកម្ពុជា??? ជាការពិណាស់! វាហាក់ដូចជាលំបាកបន្តិចមែនបើសិនយើងមើលតែទៅលើសកម្មភាពដែលមានទ្រង់ទ្រាយធំដុំផ្លូវការនោះ តែបើយើងក្រឡេកមើលទៅលើសកម្មភាពធម្មតាប្រចាំថ្ងៃរបស់យើងវិញនោះ យើងនឹងឃើញថាវាសុទ្ធសឹងតែជាប់ពាក់ព័ន្ធយ៉ាងសកម្មជាមួយនឹងការចូលរួមអភិវឌ្ឍន៏សង្គម។ នៅក្នុងការអភិវឌ្ឍន៏សង្គម ខ្ញុំបានធ្វើការបែងចែកជា៣ចំនុចសំខាន់ៗគឺ : **ការគោរពច្បាប់វិន័យសង្គម ការចូលរួមសកម្មភាពសង្គម** និង**ការបណ្តុះបណ្តាលអ្នកជំនាន់ក្រោយ។** ទោះបីជា

សកម្មភាពទាំងនេះវាមានលក្ខណៈសាមញ្ញមិនសូវជាមានឥទ្ធិពលយ៉ាងណាក៏ដោយ តែបើសិនជាយើងទាំងអស់គ្នាដែលជាយុវជន ជាប្រជាពលរដ្ឋខ្មែរគ្រប់រូប ចូលរួមគិត ចូលរួមធ្វើទាំងអស់គ្នានោះ សង្គមយើងប្រទេសជាតិយើងពិតជាអាចទទួលបាននូវការរីកចំរើន ការជឿនលឿនលូតលាស់ទៅមុខយ៉ាងឆាប់រហ័សជាក់ជាមិនខានឡើយ ។ វាពិតជារឿងដ៏ត្រឹមត្រូវបំផុត ក្នុងនាមយើងជាយុវជនម្នាក់ និងជាប្រជាពលរដ្ឋម្នាក់នៅក្នុងសង្គមមួយ ឬប្រទេសមួយ យើងត្រូវតែគោរព និងប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួននូវរាល់ក្បួនច្បាប់ ក្បួនវិន័យ ក្រមសីលធមិ ប្រពៃណីទំនៀមទំលាប់ល្អៗទាំងអស់នៅក្នុងប្រទេសខ្លួន។ យ៉ាងណាមិញកម្ពុជាក៏ជារដ្ឋមួយ និងជាប្រទេសមួយដែលមានក្បួនច្បាប់ ក្បួនវិន័យ ក្រមសីលធម៌ ប្រពៃណីទំនៀមទំលាប់ល្អៗក្នុងការអប់រំដឹកនាំប្រជាជនរបស់ខ្លួន និងក្នុងការដឹកនាំប្រទេសរបស់ខ្លួន ហើយកម្ពុជាជាប្រទេសមួយដែលអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស[៤] និងប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញដែលគោរពគោលការណ៏ច្បាប់ជាធំ ពោលគឺកម្ពុជារដ្ឋមួយដែលការដឹកនាំទាំងអស់ត្រូវស្ថិតក្រោមអំណាចនៃច្បាប់ដែលមានស្ថាប័នធំៗទាំងបីជាដំណាងគឺ នីតិបញ្ញាតិ នីតិប្រតិបត្តិ និងតុលាការ ដូចនេះក្នុងនាមខ្ញុំជាយុវជនកម្ពុជាម្នាក់ ខ្ញុំត្រូវគោរពឱ្យបានខ្ជាប់ខ្ជួនបំផុតនូវបទបញ្ញាត្តិ គោលការណ៏ និងនិយាមទាំងអស់នោះដែលកម្ពុជាមាន។ ក្រៅពីនេះទៀតបន្ទាប់ពីខ្ញុំក្លាយខ្លួនជាអ្នកគោរពវិន័យ គោរពច្បាប់សង្គមហើយនោះ ក្នុងនាមខ្ញុំជាប្រជាពលរដ្ឋល្អមានវិន័យម្នាក់ខ្ញុំពិតជាមិនអាចមិនចូលរួមក្នុងសកម្មភាពសង្គមបាននោះទេ។ ពោលគឺនៅក្នុងសង្គមមួយតែងតែមានដោយមិនអាចខ្វះបាននូវសកម្មភាពនានាដែលជាការបង្ករអោយមានការរីកចំរើន ឬការអភិវឌ្ឍន៍នៅក្នុងសង្គមដូចជាការស្ថាបនាផ្លូវថ្នល់ ជីកប្រឡាយ ជីកស្រះទឹក ជីកអណ្តូងទឹក រើសសម្រាម កសាងសាលារៀន សំអាតទីវត្តអារាម ការដាំដើមឈើ និងសកម្មភាពផ្សេងៗទៀតជាច្រើន។ ដូចនេះខ្ញុំគប្បីត្រូវតែចូលរួមអោយបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន ហើយការចូលរួមនេះមិនចាំបាច់ឱ្យខ្ញុំត្រូវតែទៅចូលរួមដោយផ្ទាល់ទើបហៅថាជាការចូលរួមនោះទេ ខ្ញុំអាចចូលរួមតាមរយៈការចូលរួមវិភាគទានបដិភាគ ការជំរុញលើកទឹកចិត្ត ការបង្កលក្ខណៈងាយស្រួល ការចូលរួមជាជំនួយផ្នែកសំភារៈនានា និងចូលរួមផ្នែកប្រាជ្ញាស្មារតីប្រៀបដូចជាពាក្យមួយឃ្លាដែលគេបានពោលឡើងថា ***"អោយតែមានចិត្តចង់ចូលរួម ក៏ជាការចូលរួមដែរ"*** ។ ការចូលរួមជាប្រការមួយដ៏សំខាន់ដែលក្នុងនាមយើងជាយុវជនម្នាក់ ពលរដ្ឋម្នាក់ត្រូវតែបង្ហាញពីឆន្ទៈមនសិការ ស្មារតី និងឧត្តមគតិជាតិរបស់ខ្លួនយ៉ាងក្លៀវក្លាក្នុងការសរបញ្ជាក់ពីការទទួលខុសត្រូវខ្ពស់បំផុតចំពោះមុខសង្គមរបស់ខ្លួន និងប្រទេសជាតិរបស់ខ្លួន។ មិនត្រឹមតែប៉ុណ្ណោះ ខ្ញុំត្រូវតែជាអ្នកដែលមានចិត្តខ្វាយខ្វល់ព្រួយបារម្ភដោយស្វាយប្រវត្តទៅលើបញ្ហានៅក្នុងសង្គមរបស់ខ្លួន និងមានការលះបង់ខ្ពស់បំផុតដើម្បីសង្គមជាតិទោះបីស្ថិតក្នុងកាលៈទេសៈបែបណាក៏ដោយដើម្បីធ្វើជាគំរូវីរៈភាពដ៏អង់អាចក្លាហានបំផុតដល់ក្មេងៗជំនាន់ក្រោយ ប្រៀបដូចជាពាក្យមួយឃ្លាដែលគេលើកឡើងថា ***"បើស្លាប់ត្រូវស្លាប់ឱ្យខ្ពស់ បើរស់ត្រូវរស់ឱ្យល្បី"*** ។ ក្រៅពីនេះទៀតការចូលរួមអភិវឌ្ឍន៏សង្គម ក្នុងនាមខ្ញុំដែលជាយុវជនម្នាក់ ជាពលរដ្ឋសកម្មម្នាក់ និងអនាគតជាអ្នកដឹកនាំម្នាក់ទៅថ្ងៃមុខ ខ្ញុំត្រូវតែមានទំនួលខុសត្រូវខ្ពស់បំផុតក្នុងការចូលរួមបណ្តុះបណ្តាលអ្នកជំនាន់ក្រោយ។ ជាការធម្មតាទេ ចលនានៃការរស់នៅរបស់មនុស្សមានការផ្លាស់ប្តូរគ្នាពីមួយជំនាន់ទៅមួយជំនាន់តាមលក្ខណៈធម្មជាតិ ហើយបើយើងជាអ្នកជំនាន់មុនដែលមានចំនេះដឹង មានសមត្ថភាព មានប្រាជ្ញា មានសីលធមិ ឧត្តមគតិ មានការលះបង់ មានការចូលរួម តែយើងមិនបានបន្សល់ទុកចំនេះ

[៤] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា. ជំពូកទី៤ អំពីរបបនយោបាយ. មាត្រា៥១ . វាក្យខ័ណ្ឌទី១

ដឹងគុំរូក្បួនច្បាប់ដល់អ្នកជំនាន់ក្រោយទេនោះ នៅពេលដែលផុតពីជំនាន់យើងទៅហើយក្មេងៗកូនចៅជំនាន់ក្រោយរបស់យើងនឹងមានការលំបាក និងជួបឧបសគ្គជាច្រើនព្រោះពួកគេត្រូវសិក្សាស្រាវជ្រាវជាថ្មីម្តងទៀតនូវក្បួនច្បាប់ ក្បួនវិន័យ ឬក្បួនតម្រាដែលជាប្រភពនៃចំនេះដឹងដ៏សំខាន់ក្នុងការរស់នៅប្រចាំថ្ងៃរបស់ពួកគេ ក៏ដូចជាក្នុងការដឹកនាំប្រទេសជាតិទាំងមូលទៅថ្ងៃអនាគតដែលជាហេតុធ្វើឱ្យប្រទេសជាតិមានការអភិវឌ្ឍន៏យឺតទៅៗ ហើយបើយើងនៅតែបន្តនូវសកម្មភាពបែបនេះពីមួយជនាន់ទៅមួយជំនាន់ទៀតនោះ នៅថ្ងៃអនាគតប្រទេសជាតិយើងនឹងក្លាយទៅជាប្រទេសមួយដែលស្ថិតនៅក្នុងស្ថានភាពក្រីក្រតោកយ៉ាកលំបាក់វេទនាកាន់តែខ្លាំងឡើងៗ ពោលគឺប្រទេសយើងនឹងក្លាយទៅជាប្រទេសដែលមានវិបត្តិសង្គម នយោបាយ និងសេដ្ឋកិច្ចជាក់ជាមិនខានឡើយ។ ការបណ្តុះបណ្តាលអ្នកជំនាន់ក្រោយយើងត្រូវតែមានឆន្ទៈប្រាជ្ញាស្មារតីខ្ពស់ក្នុងការចូលរួមចំណែកចែករំលែក ផ្ទេចំណេះដឹង បទពិសោធន៏ល្អៗដល់ក្មេងជំនាន់ក្រោយ ឬអ្នកស្រករក្រោយដែលនៅក្បែរៗខ្លួនយើង។

## សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយយ៉ាងក្បោះក្បាយ និងពិសស្តារដែលទាក់ទងទៅនឹងប្រធានបទខាងលើនេះ ខ្ញុំអាចធ្វើការសរុប និងវាយតម្លៃបានថា ក្នុងនាមខ្ញុំជាយុវជនម្នាក់នៅជំនាន់នេះនិងជាមេដឹកនាំម្នាក់នៅជំនាន់ក្រោយ ខ្ញុំអាចចូលរួមសកម្មភាពដើម្បីឱ្យប្រទេសកម្ពុជាមានការរីកចំរើន អភិវឌ្ឍន៏ជឿនលឿនលូតលាស់លើគ្រប់វិស័យទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ ទំនាក់ទំនង់អន្តរជាតិ ការទូតយោធា និងវិស័យផ្សេងៗទៀតជាច្រើនទៀតដោយខ្ញុំគោរព និងអនុវត្តន៏យ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ទាំង៣ចំនុចសំខាន់ៗខាងលើនេះ គឺ : ចំនុចទី១: **ការចូលរួមអភិវឌ្ឍន៏ខ្លួនឯង** ,ចំនុចទី២: **ការចូលរួមអភិវឌ្ឍន៏ក្រុមគ្រួសារ,** និង ចំនុចទី៣: **ការចូលរួមអភិវឌ្ឍន៏សង្គមជាតិយើង** ។ ការអភិវឌ្ឍន៏ខ្លួនឯង គឺខ្ញុំត្រូវតែជាមនុស្សដែលមានចំណេះដឹង សមត្ថភាព និងមានក្រមសីលធម៌ប្រកបដោយឧត្តមគតិភ្លឺថ្លា។ ហើយបន្ទាប់ពីការអភិវឌ្ឍន៏ខ្លួនឯង ខ្ញុំត្រូវតែមានការអភិវឌ្ឍន៏ក្រុមគ្រួសារដោយមានការគិត ការនិយាយ និងការធ្វើ ពោលគឺខ្ញុំត្រូវតែដឹងនិងគោរពសិទ្ធិ នឹងតួនាទីគ្នាទៅវិញទៅមកនៅក្នុងគ្រួសារដោយស្មារតីសាមគ្គីភាពខ្ពស់បំផុត។ ក្រៅពីនេះទៀតខ្ញុំត្រូវចូលរួមក្នុងសកម្មភាពដើម្បីអភិវឌ្ឍសង្គមជាតិយើងដោយការគោរពច្បាប់ គោរពវិន័យសង្គម ការចូលរួមសកម្មភាពនានានៅក្នុងសង្គម និងការចូលរួមបណ្តុះបណ្តាលអ្នកជំនាន់ក្រោយដើម្បីឱ្យពួកគេធ្វើជាអ្នកស្នងមរតកនៃតួនាទី ភារកិច្ច កាតព្វកិច្ចក្នុងការដឹកនាំប្រទេសជាតិយើងឱ្យមានការរីកចំរើនទៅមុខជាលំដាប់នាពេលអនាគត និងដើម្បីឱ្យកម្ពុជាយើងអាចធ្វើសមាហរណកម្មខ្លួនចូលទៅក្នុងដំបន់ ក៏ដូចជាក្នុងសកលលោកនៃពិភពសកលភាវូបនីយកម្មយើងនេះ។ និយាយរួមខ្ញុំត្រូវដឹងថា ក្នុងនាមខ្ញុំជាយុវជនម្នាក់ត្រូវមានតួនាទីបែបណា? ក្នុងនាមខ្ញុំជាសមាជិកគ្រួសារម្នាក់ត្រូវមានភារៈកិច្ចអ្វីខ្លះ? ក្នុងនាមខ្ញុំជាពលរដ្ឋម្នាក់ត្រូវមានទំនួលខុសត្រូវបែបណា? ក្នុងនាមខ្ញុំជានិស្សិតម្នាក់ត្រូវធ្វើអ្វីខ្លះ? ពោលក្នុងនាមយើងជាមនុស្សម្នាក់ដែលរសនៅក្នុងសង្គម យើងត្រូវដឹង និងគោរពតួនាទីខ្លួនរៀងៗខ្លួនទើបសង្គមយើងមានការរីកចំរើនរុងរឿងទៅមុខជាលំដាប់បាន។

***" យុវជនគឺជាអ្នកដឹកនាំនាពេលអនាគត់ និងជាដៃគូអភិវឌ្ឍន៍នាពេលបច្ចុប្បន្ន "*** ប្រសាសន៍របស់លោក ខហ្វីអាណាន់ អតីតរដ្ឋលេខាធិការអង្គការសហប្រជាជាតិ។

# ឯកសារយោង

- *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*
- សូ ណារ៉ូ *"ការប្រៀបធៀបកម្លាំងនយោបាយនៅកម្ពុជាពីសន្និសីទក្រុងប៉ារីស ១៩៩១-២០០៦"* បណ្ណាគារអង្គរធំ  ភ្នំពេញខែតុលា ឆ្នាំ២០០៦
- *សេចក្តីព្រាងគោលនយោបាយជាតិយុវជនកម្ពុជា ២០០៩*
- ឈុន ណារ៉េត *"សេចក្តីផ្តើមវិទ្យាសាស្រ្តនយោបាយ"* ភ្នំពេញ ព.ស ២៥៥៣ គ.ស ២០០៨ កែសម្រួល និងបោះពុម្ពផ្សាយលើកទី៣
- សម្តេចព្រះសង្ឃរាជ ជួន ណាត *"វចនានុក្រមខ្មែរ"* ការផ្សព្វផ្សាយរបស់ពុទ្ធសាសនបណ្ឌិត រាជធានីភ្នំពេញឆ្នាំ ១៩៦៧